តើនរណា ល្ងង់ជាង នរណា ?

នៅឆ្នាំ ២០១៤ លោក សម រង្សី និង កឹម សុខា នាំគ្នាដើរចូលរដ្ឋសភាចោរ បំពានលើឆន្ទៈម្ចាស់ឆ្នោត ដោយគ្មានបារម្ភអ្វីអំពី ធម្មានុរូប នៃ ទង្វើ របស់ខ្លួននោះឡើយ។ បច្ចុប្បន្នកាលនេះ ទ្រង់ រណ្ណឫទ្ធិ ដើរចូលរដ្ឋសភាចោរ បំពានលើឆន្ទៈម្ចាស់ឆ្នោត ដោយគ្មានកង្វល់ អំពី សីលធម៌ អ្វីនោះដែរ។ តែ ទង្វើទាំងពីរនោះ វាមានធាតុតែមួយ គឺ បំរើ ផលប្រយោជន៍ លោក ហ៊ុន សែន ដូចគ្នា, ពួកទី១ ធ្វើនិត្យានុកូលកម្ម រដ្ឋសភាចោរ ១ ស្របច្បាប់ សំរាប់តែធ្វើច្បាប់បំបាត់សេរីភាព, រីឯ រណ្ណឫទ្ធិ វិញ ចូលរួម ក្នុងហាន:ជាអាមាត្យតែម្តង ទទួលយកកៅអីពុកស្ពុយ មកអង្គុយ ដូចតួកល្ខោន។ ត្រូវដឹងថា កៅអី ដែលប្តូរ អ្នកអង្គុយ គឺជា កៅអី ថោកទាប ប្លន់ពីរាស្ត្រ សំរាប់ ចែកលុយគ្នាចាយតែប៉ុណ្ណោះ ដូច្នេះ ដូរអ្នកអង្គុយ វាគ្មានអ្វី ជា អកុសលដល់ជាតិនោះឡើយ ព្រោះកៅអីនោះ តាំងពីដើមទីមក វាជាអកុសលរួចមកហើយ: ពួក អ្នកអង្គុយ ចាស់ថ្មី គឺគ្មានកិត្តិយស ដូចគ្នា មិនដូច លោក បណ្ឌិត ឡង ឫតា គាត់ថ្លែងថា អ្នកបាន អង្គុយ ត្រូវដឹងគុណ លោក សម រង្សី និង កឹម សុខា ព្រោះ លោកទាំងពីរ ជាអ្នក រកកៅអី១គាត់អង្គុយ។ គាត់និយាយបែបនេះ ដោយមិនបានគិតថា ម្ចាស់កៅអី គឺ ម្ចាស់

តើនរណា លូងជាង នរណា ?

ឆ្នោត ដែល ពួក អស់លោក នាំគ្នាយកមកអង្គុយ ដោយក្បត់ធ
ន្ទ:រាស្ត្រ ហើយគ្មានស្មារតី ជា បញ្ញាជននោះទេ។ បណ្ឌិត ឡូង ឬ
តា គាត់ ដឹងគុណលោក សម រង្សី រឺ ឯ បណ្ឌិត រណ្ណឬទ្ធិ គាត់ ដឹង
គុណលោក ហ៊ុន សែន សួរថា តើមានអ្នកណាទៅហ្ន ដែលជាអ្នក
ដឹងគុណ ប្រជាពលរដ្ឋ ដែលជា ម្ចាស់ឆ្នោត ? ប្រហែលជា បណ្ឌិត
សុខ ទូច មើលទៅ ? ហេតុនេះឯង បានជា បណ្ឌិតនេះ ក្លាយជា
ប្រធាន ពួកបណ្ឌិត នៅស្រុកខ្មែរ។ មួយវិញទៀត អ្នកមានគុណ
លើ បណ្ឌិត ឡូង ឬ ឬ គាត់មាន យុទ្ធសាស្ត្រ រក្សា រចនាសម្ព័ន្ធ
គណបក្សសង្គ្រោះជាតិ ដើម្បី សំរាប់ ធ្វើការចរចា ជាមួយលោក
ហ៊ុន សែន តែ រចនាសម្ព័ន្ធ ដឹកនាំដោយ ពួកអ្នកដឹកនាំ
ដដែល ដែលសុទ្ធជាអ្នកចាញ់ គឺច្បាស់ជា លទ្ធផល រានឹងចាញ់
ដដែល ដូចគ្នានឹង គណបក្ស ហ្វ្រុនស៊ីនប៉ិច នោះដែរ។ មិនមែន
រចនាសម្ព័ន្ធទេ ជា បញ្ហា នៃ ការតស៊ូ គឺពួកអ្នកដឹកនាំ ជា ច
លករ ឬ បញ្ហា ទាញ រចនាសម្ព័ន្ធ អោយដើរទៅមុខ។ បើ ពួក
អ្នកដឹកនាំ គាត់លូង គឺច្បាស់ជា រចនាសម្ព័ន្ធ រាគ្រាន់តែ ជា
ឡាន ក្ងានសាំងចាក់នោះឯង។ មកដល់ចំណុចនេះ យើងសួរថា
តើថ្នាក់ដឹកនាំ គណបក្សសង្គ្រោះជាតិ និង ហ្ន្ទ្រ៉ូនស៊ីនប៉ិច មិន
ដឹងជា នរណាលូងជាងនរណាទេ ? ព្រោះសុទ្ធតែធ្លាប់មាន ជន
ខ្មែរ រាប់លាននាក់ គាំទ្រ តែបែរជាមាន មារយាទ គម្រក់
ក្រៃពេកបែបនេះ។ សួរថា ខំដើរតួជា អ្នករងគ្រោះ និង មាន
អ្នកមានគុណ សំរាប់អរគុណ តើវាគ្រប់គ្រាន់ សំរាប់ប្រឈរមុខ
ទល់នឹងអំណាចផ្តាច់ការ រណបយួន បានដែរឬទេ ?